**WWF-Cambodia**

21, Street 322,
BoeungKeng Kang I,
Phnom Penh, Cambodia
P.O. Box: 2467

Tel: +855 23 218 034
Fax: +855 23 211 909

www.cambodia.panda.org
www.panda.org/greatermekong
wwfcambodia@wwfgreatermekong.org

*for a living planet*®

**PRESS RELEASE** | **For Immediate Release**

# មនុស្សជាង ១000 នាក់ នឹងអបអរសាទរភាពជោគជ័យ ក្នុងការអភិរក្សសត្វផ្សោតទន្លេមេគង្គក្នុងទិវាសត្វផ្សោតទន្លេមេគង្គក្នុងទីរួមខេត្តក្រចេះ

## រដ្ឋបាលជលផលកម្ពុជា មន្ទីរទេសចរណ៍ខេត្តក្រចេះ និងអង្គការ WWF-កម្ពុជា រៀបចំព្រឹត្តិការណ៍រួមគ្នា ដើម្បីជម្រុញការចូលរួមដោះស្រាយបញ្ហាប្រឈមនានាដែលគម្រាមកំហែងដល់សត្វផ្សោតទន្លេមេគង្គ

ខេត្តក្រចេះ ព្រះរាជាណាចក្រកម្ពុជា៖ ទិវាសត្វផ្សោតទន្លេមេគង្គឆ្នាំនេះ ជាទិវាដែលធំបំផុតដែលមិនធ្លាប់បានប្រារព្ធធ្វើពីមុនៗមក ដោយសារតែទិវាឆ្នាំនេះ នឹងមានអ្នកចូលរួមក្នុងកម្មវិធីប្រហែលជាង ១000 នាក់ ហើយវាជាលើកដំបូងបំផុតដែលទិវានេះ មានការចូលរួមពីក្រុមហ៊ុនឯកជនធំៗ និងបន្តក្តីសង្ឃឹមដែលចំនួនសត្វផ្សោតទន្លេមេគង្គអាចស្តារឡើងវិញបាននៅក្នុងតំបន់ទេសភាពព្រៃលិចទឹកមេគង្គ។

ទិវាសត្វផ្សោតទន្លេមេគង្គដែលប្រារព្ធធ្វើឡើងចាប់ពីថ្ងៃទី២៥ ដល់ទី២៧ ខែតុលា ឆ្នាំ២០១៩ នឹងប្រមូលផ្តុំអ្នកចូលរួមប្រមាណជាង ១000 នាក់ ដែលជាតំណាងមកពីស្ថាប័នរាជរដ្ឋាភិបាល ក្រុមហ៊ុនឯកជន អង្គការដៃគូ សិស្សនិស្សិត យុវជន សហគមន៍ ភ្ញៀវទេសចរ និងប្រជាពលរដ្ឋក្នុងទីរួមខេត្តក្រចេះ។ ក្នុងទិវានេះ មានកម្មវិធីជាច្រើនដើម្បីផ្សព្វផ្សាយ អប់រំ និងលើកកម្ពស់ការយល់ដឹងអំពីទំនាក់ទំនងរវាងការអភិរក្សសត្វផ្សោតទន្លេមេគង្គទៅនិងវិស័យទេសចរណ៍ធម្មជាតិ និងជីវភាពរបស់ប្រជាពលរដ្ឋមូលដ្ឋាន។ អ្នកចូលរួមទាំងអស់អាចចូលរួមក្នុងយុទ្ធនាការដាំដើមឈើ កម្មវិធីដើរក្បួន កម្មវិធីរត់ប្រណាំង កម្មវិធីជិះកង់ កម្មវិធីប្រកួតប្រជែងយករង្វាន់ ការតាំងពិព័រណ៍ផលិតផល និងកម្មវិធីតន្ត្រីកំសាន្ត។

អង្គការ WWF-កម្ពុជា រៀបចំទិវានេះក្រោមកិច្ចសហការជាមួយរដ្ឋបាលជលផល មន្ទីរទេសចរ និងរដ្ឋបាលខេត្តក្រចេះ។ ទិវានេះក៏ទទួលបានកិច្ចសហប្រតិបត្តិការគាំទ្រជាលើកដំបូងបង្អស់ពីក្រុមហ៊ុនឯកជនដូចជាក្រុមហ៊ុន មេរ៉ុ មីក្រូហិរញ្ញវត្ថុ ហត្ថាកសិករ និងក្រុមហ៊ុនទូរស័ព្ទមិត្តហ្វូន។

ក្នុងឆ្នាំ២០១៨ អង្គការ WWF-កម្ពុជា រដ្ឋបាលជលផល និងដៃគូអភិរក្សនានា បានប្រារព្ធពិធីអបអរសាទរចំពោះកំណើនចំនួនសត្វផ្សោតទន្លេមេគង្គជាលើកដំបូងបំផុតក្នុងរយៈពេល ២0 ឆ្នាំ។ កំណើនចំនួនសត្វផ្សោតលើកដំបូងគេនោះ ជាកំណើន ១៥% នៃកំណើនចំនួនសត្វផ្សោតពី ៨0 ក្បាល ក្នុងឆ្នាំ២០១៥ ទៅដល់ ៩២ ក្បាល ក្នុងឆ្នាំ២០១៧។ នាបច្ចុប្បន្ននេះ ការអង្កេតចំនួនសត្វផ្សោតទន្លេមេគង្គថ្មីមួយទៀតកំពុងតែដំណើរការ ហើយក្រុមការងារអភិរក្សយ៉ាងច្រើនមានក្តីសង្ឃឹមថានឹងមានកំណើនចំនួនសត្វផ្សោតទន្លេមេគង្គម្តងទៀត។ ក្តីសង្ឃឹមនេះកើតមានឡើងដោយសារតែ បើគិត

ចាប់តាំងពីការអង្កេតចំនួនសត្វផ្សោតពេលចុងក្រោយ មកដល់បច្ចុប្បន្ននេះ យើងបានកត់ត្រាឃើញថា ចំនួនកូនផ្សោតកើតថ្មីមានចំនួន ២០ ក្បាល ខណៈដែលចំនួនសត្វផ្សោតដែលស្លាប់មានតែ ០៩ ក្បាលប៉ុណ្ណោះ។

"លទ្ធផលនៃការអង្កេតចំនួនសត្វផ្សោតទន្លេមេគង្គឆ្នាំមុន យើងបានឃើញនូវរបត់ផ្លាស់ប្តូរនៃការធ្លាក់ចុះចំនួនសត្វផ្សោតទន្លេមេគង្គ។ ការធ្លាក់ចុះនៃចំនួនសត្វផ្សោតក្នុងរយៈពេល ២០ ឆ្នាំកន្លងមកនេះ ជាចុងក្រោយអាចកើនឡើងវិញជាលើកដំបូងបង្អស់" ប្រសាសន៍របស់លោក សេង ទៀក នាយកអង្គការ WWF-កម្ពុជា។ "ទិវាសត្វផ្សោតទន្លេមេគង្គជាឱកាសមួយដើម្បីអបអរសាទរភាពជោគជ័យ និងការបន្តភាពប្តេជ្ញាចិត្តរបស់យើងក្នុងការធានាបានថាសត្វផ្សោតទន្លេមេគង្គរបស់កម្ពុជានៅតែគង់វង្ស តាមរយៈកិច្ចប្រឹងប្រែងធ្វើការរួមគ្នាជាមួយរដ្ឋាភិបាល ដៃគូអភិរក្ស សហគមន៍មូលដ្ឋាន និងវិស័យឯកជន។"

កត្តាគម្រាមកំហែងធ្ងន់ធ្ងរទៅលើសត្វផ្សោតគឺការអនុវត្តការនេសាទខុសច្បាប់ ជាពិសេសគឺការដាក់មងក្នុងតំបន់ការពារសត្វផ្សោត។ ទំនប់វារីអគ្គិសនីដែលកំពុងស្ថិតនៅក្រោមការសាងសង់ និងគម្រោងទំនប់វារីអគ្គិសនីនានាកាត់ទន្លេមេគង្គក៏បង្កឱ្យមានការព្រួយបារម្ភយ៉ាងខ្លាំងក្លាចំពោះភាពរស់រានមានជីវិតរបស់សត្វផ្សោត និងជីវភាពរបស់សហគមន៍មូលដ្ឋាននាពេលអនាគតផងដែរ។

ដោយសារតែចំនួនសត្វផ្សោតទន្លេមេគង្គដែលជាប្រភេទសត្វទទួលរងគ្រោះថ្នាក់ជិតផុតពូជបំផុត មានតែ ៩២ ក្បាលប៉ុណ្ណោះក្នុងទន្លេមេគង្គ ចំនួននេះជាចំនួនតិចតួចបំផុត បើធៀបនឹងចំនួនរបស់វាដែលធ្លាប់មានរហូតដល់ជាង ៣០០០ ក្បាល រស់នៅតាមដងទន្លេមេគង្គ និងបឹងទន្លេសាប កាលពីប្រហែលជាងមួយសតវត្សមុន។ អង្គការ WWF រាជរដ្ឋាភិបាល និងដៃគូអភិរក្សនានា បាននឹងកំពុងខិតខំធ្វើការយ៉ាងខ្លាំងដើម្បីអភិរក្សប្រភេទសត្វផ្សោតនេះ តាមរយៈការងារពង្រឹងច្បាប់ឱ្យបានតឹងរឹង ការកាត់បន្ថយ និងលុបបំបាត់ចោលនូវការនេសាទខុសច្បាប់នានាក្នុងតំបន់ការពារសត្វផ្សោត ការអប់រំផ្សព្វផ្សាយ ការស្រាវជ្រាវ និងត្រួតពិនិត្យតាមដានសត្វផ្សោត ព្រមទាំងកម្មវិធីផ្តល់ជម្រើសជីវភាពជាច្រើនដល់សហគមន៍មូលដ្ឋាន។ ការផ្តោតសំខាន់លើកិច្ចការចម្បងថ្មីមួយទៀតនោះ គឺការជម្រុញឱ្យមានការប្រើប្រាស់ថាមពលកកើតឡើងវិញប្រកបដោយនិរន្តរភាពដូចជាជម្រើសថាមពលពន្លឺព្រះអាទិត្យ និងថាមពលខ្យល់ ជំនួសឱ្យគម្រោងទនប់វារីអគ្គិសនី ដែលបង្កការគម្រាមកំហែងលើអាយុជីវិតសត្វផ្សោតទន្លេមេគង្គ។

"យើងបានទទួលលទ្ធផលជាប្រវត្តិសាស្ត្រក្នុងការងារអភិរក្សសត្វផ្សោតទន្លេមេគង្គ ដែលកើតចេញពីកិច្ចខិតខំប្រឹងប្រែង និងការប្តេជ្ញាចិត្តរបស់យើងទាំងអស់គ្នា។ ពួកយើងនឹងបន្តកិច្ចខិតខំប្រឹងប្រែងរបស់យើង ដើម្បីដោះស្រាយបញ្ហាប្រឈមនានា ហើយសង្ឃឹមថាយើងអាចទទួលបានលទ្ធផលល្អមួយកម្រិតទៀត។" ប្រសាសន៍របស់ឯកឧត្តម អេង ជាសាន ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកអគ្គនាយករដ្ឋបាលជលផលកម្ពុជា នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង៖
លោក ផា ស៊ីណា មន្ត្រីផ្នែកទំនាក់ទំនង នៃអង្គការ WWF-កម្ពុជា
អ៊ីម៉ែល៖ sina.pha@wwf.org.kh

អំពីអង្គការ WWF-កម្ពុជា

អង្គការ WWF បានបង្កើតឡើងនៅក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ ១៩៩៨ ដែលជាផ្នែកមួយនៃអង្គការ WWF ក្នុងមហាតំបន់ទន្លេមេគង្គ។ បេសកកម្មរបស់អង្គការ WWF គឺជានាឱ្យមានការចូលរួមគាំទ្រពីមនុស្សគ្រប់រូបដើម្បីធ្វើការអភិរក្សនូវជីវៈចម្រុះដ៏សម្បូរបែបនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ អង្គការ WWF-កម្ពុជា នឹងជម្រុញឱ្យមានឱកាសថ្មីៗជាច្រើនដែលផ្តល់ផលប្រយោជន៍ដល់មនុស្ស និងធ្វើឱ្យប្រសើរឡើងនូវកម្រិតជីវភាពរបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋាន ព្រមទាំងចូលរួមកាត់បន្ថយភាពក្រីក្រ តាមរយៈការលើកទឹកចិត្តឱ្យមានការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព។ សម្រាប់ព័ត៌មានលម្អិត សូមចូលទៅកាន់គេហទំព័ររបស់អង្គការ WWF-កម្ពុជា៖ wwf.org.kh